អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាជាតិ
# អំពីមរណភាពរបស់ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច

សហព្រះរាជអាជ្ញាជាតិ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច បានទទួលមរណភាព នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត វេលាម៉ោង ០០:៥១ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២០ នេះ។

ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិខ្មែរ មុខរបរគ្រូបង្រៀន ជាប្រធានមន្ទីរសន្តិសុខ ស-២១។ គាត់ត្រូវបានចាប់ និងឃុំខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានផ្ទេរមកឃុំខ្លួនក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងអំពើទារុណកម្ម និងមនុស្សឃាត ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការដើម្បីជំនុំជម្រះលើ កាំង ហ្កេកអ៊ាវ ហៅ ឌុច ហើយបានធ្វើសវនាការដេញដោលភស្តុតាង ស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចំណាយពេលវេលាអស់រយៈពេល ៧២ថ្ងៃ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ សាលក្រមត្រូវបានប្រកាស ដោយបានរកឃើញថា កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខ ស-២១ អស់រយៈពេលជាង ៣ ឆ្នាំ ដែលបណ្តាលឱ្យមានការសម្លាប់ជនរងគ្រោះជាង ១២២៧២ នាក់។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផ្តន្ទា

ទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ពីបទការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ នៃបទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ត្រូវបានសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាសម្រេចផ្ដន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត។

កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្ដាល នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៣ ដើម្បីអនុវត្តទោស បន្ទាប់ពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។

ថ្ងៃនេះ សហព្រះរាជអាជ្ញាជាតិ ជូនដំណឹងថា កាំង ហ្គេកអ៊ាវ ហៅ ឌុច បានទទួលមរណភាព ដោយផ្អែកតាមរបាយការណ៍របស់មន្ត្រីពាក់ព័ន្ធ ហើយចំពោះការស៊ើបអង្កេតពាក់ព័ន្ធនឹងមូលហេតុនៃមរណភាពរបស់ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**លោក នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.phektra@eccc.gov.kh